## រឿងទី៩៖ យ៉ាកុប១ (យ៉ាកុប និងអេសាវ)

**ខគម្ពីរ៖ លោកុប្បត្តិ២៥៖៣៣**

លោកយ៉ាកុបពោលថា៖ «ដូច្នេះ ចូរស្បថឲ្យខ្ញុំសិន»។ លោកអេសាវក៏ស្បថលក់សិទ្ធិជាកូនច្បងឲ្យលោកយ៉ាកុប។

អ៊ីសាកនិងរេបិកាបានបង្កើតកូនប្រុសភ្លោះពីរនាក់។

កូនដែលកើតមកមុននោះមានស្បែកពណ៌ក្រហម និងមានរោមច្រើន។

អ៊ីសាកបានដាក់ឈ្មោះឱ្យកូននោះថា «អេសាវ»

ហើយកូនប្អូនដែលកើតមកក្រោយទាំងតោងកែងជើងរបស់អេសាវជាប់នោះ ដាក់ឈ្មោះថា «យ៉ាកុប»។

ពេលធំពេញវ័យ អេសាវបានក្លាយជាប្រមាញ់ដ៏អង់អាចម្នាក់។

ចំណែកយ៉ាកុបវិញ គាត់ជួយកិច្ចការក្នុងផ្ទះនិងមើលថែទាំសត្វ។

នៅថ្ងៃមួយ យ៉ាកុបកំពុងស្លសម្ល ហើយអេសាវបានវិលត្រឡប់មកពីប្រមាញ់វិញ គាត់ឃ្លានខ្លាំងណាស់។

អេសាវក៏និយាយទៅប្អូនគាត់ថា៖ «យ៉ាកុប! ឱ្យបងសុំសម្លញ៉ាំបន្តិចបានទេ?»

យ៉ាកុបបានឆ្លើយថា៖ «បើអ៊ីចឹង បងលក់សិទ្ធិជាបងច្បងឱ្យខ្ញុំនៅថ្ងៃនេះសិនមក ខ្ញុំនឹងឱ្យសម្លបងញ៉ាំ»។

អេសាវ មិនបានគិតថាសិទ្ធជាបងច្បងនេះសំខាន់ប៉ុណ្ណាទេ ហើយធ្វើតាមអ្វីដែលយ៉ាកុបនិយាយ។

ពេលវេលាចេះតែកន្លងទៅ អ៊ីសាកកាន់តែចាស់ ភ្នែកគាត់ចាប់ផ្ដើមងងឹតមើលមិនសូវច្បាស់។

មានថ្ងៃមួយ អ៊ីសាកបានហៅអេសាវមករួចនិយាយថា៖

«អេសាវអើយ ចូរកូនចេញទៅប្រមាញ់សត្វហើយយកវាមកធ្វើម្ហូបដែលពុកចូលចិត្តមកឱ្យពុកហូបមក។ នោះពុកនឹងឱ្យពរនៃព្រះជាម្ចាស់ដល់កូន»។

រេបិកាបានលបស្ដាប់លឺការនិយាយគ្នារបស់អ៊ីសាកនិងអេសាវ។

រេបិកាបានហៅយ៉ាកុបមកប្រាប់៖ «យ៉ាកុប ចូរកូនទៅយកកូនពពែធាត់ល្អពីក្នុងក្រោលមួយក្បាលមក។ បើកូនជាអ្នកទទួលបានពរនោះ ម៉ែសប្បាយចិត្តណាស់។»

រេបិកាបានយកពពែដែលយ៉ាកុបបានយកមក រៀបចំធ្វើម្ហូបដែលអ៊ីសាកចូលចិត្ត។





ហើយយកសម្លៀកបំពាក់របស់អេសាវមកបំពាក់ឱ្យយ៉ាកុប។

និងបានយករោមពពែមករុំនៅក និងដៃរបស់យ៉ាកុប។

យ៉ាកុប បានលើកម្ហូបដែលម្ដាយគាត់បានធ្វើរួចនោះ ទៅជូនឪពុក។

យ៉ាកុបភ័យខ្លាំង ខ្លាចត្រូវឪពុកដឹង។ អ៊ីសាកបានយកដៃស្ទាបយ៉ាកុប។

អ៊ីសាកគាត់ចាស់ហើយភ្នែកមើលមិនច្បាស់ ក៏យកដៃស្ទាបទៅប៉ះរោមនៅលើខ្លួន ក៏គិតថាកូននោះពិតជាអេសាវមែន។ អ៊ីសាកបានបរិភោគយ៉ាងឆ្ងាញ់ ហើយបានឱ្យពរដល់យ៉ាកុប។

មិនយូរប៉ុន្មាន អេសាវក៏ត្រឡប់មកវិញហើយធ្វើម្ហូបយកឱ្យឪពុកបរិភោគ។

អ៊ីសាកបាននិយាយទៅអេសាវថា៖ «មុននេះបន្តិច ដោយពុកគិតថាម្នាក់នោះជាកូន ទើបពុកបានឱ្យពរដល់គេ»។

អេសាវ ខឹងសម្បារជាខ្លាំង។ គាត់ចាប់ផ្ដើមស្អប់យ៉ាកុបជាប្អូន។

និងបានសម្រេចថា៖ «ពេលពុកស្លាប់ទៅ យើងនិងសម្លាប់ឯង យ៉ាកុប»

រេបិកាបានលបស្ដាប់អេសាវនិយាយ។

ហើយក្រោយមក យ៉ាកុបដែលត្រូវបានអេសាវជាបងស្អប់នោះ បានរត់គេចទៅរស់នៅផ្ទះរបស់អ៊ំគាត់។

● សូមសរសេរតាមខគម្ពីរខាងក្រោម រួចទន្ទេញ។ (លោកុប្បត្តិ២៥៖៣៣)

លោកអេសាវក៏ស្បថលក់សិទ្ធិជាកូនច្បងឲ្យលោកយ៉ាកុប។





**សកម្មភាពទី១** សូមកាត់គ្រឿងផ្សំដែលត្រូវយកមកធ្វើបបរ រួចបិទវានៅក្នុងឆ្នាំងធំ។





**សកម្មភាពទី២** សូមគិតពីខ្លឹមសារមេរៀនដែលបានរៀននៅថ្ងៃនេះ រួចផាត់ពណ៌រូបភាពខាងក្រោម។

